ខោនធី ឃីង

# ប្រកាសន៍ ភាពឯកជន

## អារម្ភកថា

ខោនធី ឃីង គឺជាអង្គភាពមួយនៃរដ្ឋាភិបាល បំពេញកិច្ចការសាធារណៈ និងកំណត់ត្រារបស់ខ្លួន ជាប់ទាក់ទងនឹងកិច្ចការនៃខោនធី ឃីង ដែលជាទូទៅមានសំរាប់ឲ្យសាធារណជនមើល ។ ទោះជាយ៉ាងណាក៏ដោយ ខោនធី ឃីង បានប្តេជ្ញាទៅតាមវិសាលភាពនៃច្បាប់ដែលបានអនុញ្ញាត ដើម្បីការពារ និងរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដែលមាននៅក្នុងកំណត់ត្រានៃខោនធី ឃីង ឲ្យបានបិតថេរ ។ ការប្តេជ្ញាចំពោះភាពឯកជននេះ ត្រូវតែបានថ្លឹងថ្លែងស្របជាមួយនឹងសិទ្ធិឲ្យសាធារណៈអាចមើលបាន នៅក្រោមវគ្គ 42.17 RCW (ក្រឹត្យបើកសំដែងព័ត៌មានសាធារណៈ រដ្ឋវ៉ាស៊ីងតុន) ព្រមទាំងស្របតាមច្បាប់ KCC 2.14.030 ហើយនិងលក្ខន្តិកៈ ឬបញ្ញត្តិជាធរមានផ្សេងៗទៀតនៃរដ្ឋាភិបាលសហព័ន្ធ រដ្ឋ និងរដ្ឋាភិបាលតាមតំបន់ ។

ប្រកាសន៍ភាពឯកជន គឺសេចក្តីជូនដំណឹងអំពីភាពឯកជននេះ មិនពាក់ព័ន្ធចំពោះសំណុំរឿងផ្ទាល់ខ្លួន, ការដាក់ពាក្យសុំការងារធ្វើ, កំណត់ត្រាតុលាការ ការស៊ើបអង្កេតនៃភ្នាក់ងារនគរបាល, ការស៊ើបអង្កេតបញ្ញត្តិ, អ្នកប្រមាណមើលកំណត់ត្រា, និងឯកសារដែលបានរក្សាទុកដោយផ្នែកខាងកំណត់ត្រា, ការបោះឆ្នោត, និងខាងការចេញសំបុត្រអនុញ្ញាតឡើយ ។

## ព័ត៌មានភាពឯកជន

ខោនធី ឃីង ប្រមូលព័ត៌មានផ្ទាល់ខ្លួន នៅពេលវាជាប់ទាក់ទង និងជាចាំបាច់ ដើម្បីសំរេចកិច្ចការរបស់ខោនធី ។ យើងបានព័ត៌មាននេះមកតែតាមរយៈលក្ខណៈស្របច្បាប់ប៉ុណ្ណោះ ។ នៅពេលខោនធី ឃីង ប្រមូលព័ត៌មានផ្ទាល់ខ្លួនពីអ្នក យើង :

- ប្រាប់អ្នកអំពីមូលហេតុដែលយើងប្រមូលព័ត៌មានផ្ទាល់ខ្លួននេះ ។
- កំរិតចំនួននៃព័ត៌មានផ្ទាល់ខ្លួនដែលយើងប្រមូល ដែលជាចាំបាច់ចំពោះអ្វី សំរាប់គោលបំណងដែលបានថ្លែង ។
- ចាត់វិធានការយ៉ាងសមហេតុសមផល ដើម្បីប្រើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ទៅតាមគោលបំណងដែលបានថ្លែង ។
- ចាត់វិធានការ ដើម្បីធ្វើឲ្យប្រាកដថា ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកគឺត្រឹមត្រូវ សព្វគ្រប់ និងទាន់ពេលបច្ចុប្បន្ន ។
- ផ្តល់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ទៅឲ្យបុគ្គលិកខោនធី ឃីង និងអ្នកម៉ៅការឯកជន ដែលបានអនុញ្ញាត ឬអង្គការសាធារណៈ ទៅតាមពេលវេលាដែលត្រូវការ ។
- មិនលក់ ឬធ្វើឲ្យព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក មានសំរាប់អ្នកផ្សេងៗ ដោយពុំមានសេចក្តីយល់ព្រមពីអ្នកឡើយ លើកលែងតែនៅពេលច្បាប់បានដំរូវ ត្រូវការដើម្បីបំពេញកិច្ចការរបស់អ្នកជាមួយនឹងខោនធី ឬនៅក្នុងករណីអាសន្នខ្លាំង ដែលនាំឲ្យមានរបួសធ្ងន់ធ្ងរ ឬបាត់បង់ជីវិត ។
- រក្សាព័ត៌មានផ្ទាល់ខ្លួនជាដរាប តាមការចាំបាច់តែប៉ុណ្ណោះ ដើម្បីបំពេញកិច្ចការរបស់ខោនធី ឬទៅតាមវិសាលភាពដែលច្បាប់បានដំរូវតែប៉ុណ្ណោះ ។
- បំផ្លាញចោលព័ត៌មានផ្ទាល់ខ្លួន នៅក្នុងលក្ខណៈមួយបិតថេរ ដែលរាំងរាដល់ការបើកសំដែង ។
- ចាត់វិធានការដោយមានសណ្តាប់ធ្នាប់ តាមបច្ចេកវិជ្ជា និងជាក់ស្តែង ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនឲ្យបិតថេរ ។

## ព័ត៌មានភាពឯកជនជាក់លាក់ ចំពោះអ៊ិនទ័រណិត

យើងក៏ប្រមូលព័ត៌មានដាក់នៅលើវ៉ិបសៃអ៊ិនទ័រណិតរបស់យើងដែរ ទាំងព័ត៌មានឥតបញ្ចេញឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួន ។

- ព័ត៌មានឥតបញ្ចេញឈ្មោះ មិនអាចតភ្ជាប់ទៅនឹងមនុស្សណាម្នាក់ឡើយ ដូចជាអ្នកប្រើចូលមកមើល ចំនួនដងចូលមក និងពេលវេលា ដែលយើងតាមដាន ដោយអ្នកផ្តល់សេវាអ៊ីនទ័រណិត ។ យើងប្រើព័ត៌មាននេះដើម្បីជួយយើងបង្កើតនូវការពិសោធន៍ទូទៅឲ្យបានប្រសើរឡើង សំរាប់អ្នកប្រើវ៉ិបសៃរបស់យើង ។
- កំទេចពាក្យ ឬសំរាយហៅថា ឃុគឃី គឺជាឧទាហរណ៍មួយទៀតនៃព័ត៌មានឥតបញ្ចេញឈ្មោះ ដែលយើងប្រើ ។ ឃុគឃីនៃវ៉ិបសៃ គឺជាសំណុំរឿងពាក្យតូចៗ ដែលបានដាក់ក្នុងកុំព្យូទ័ររបស់អ្នកប្រើ ដោយប្រព័ន្ធបណ្តាញអ៊ិនទ័រណិត ។ យើងប្រើឃុគឃីម្តងម្កាល ដើម្បីកែព័ត៌មានឲ្យស្របទៅតាមសេចក្តីត្រូវការជាក់លាក់ នៃប្រដាប់មើលអ៊ិនទ័រណិតរបស់អ្នកប្រើ ។ ប្រព័ន្ធបណ្តាញអ៊ិនទ័រណិតរបស់យើង មិនអាចសំរេចទិន្នន័យណាមួយអំពីរូបអ្នកបានឡើយ ហើយក៏មិនធ្វើអ្វីសោះជាមួយនឹងឃុគឃីទាំងនេះដែរ ។
- ព័ត៌មានផ្ទាល់ខ្លួន ដែលបានប្រមូលនៅលើទំព័រវ៉ិបសៃណាមួយរបស់ខោនធី យីង គឺជាទិន្នន័យដែលអ្នកផ្តល់ឲ្យយើងស្តីអំពីរូបអ្នក ។ ការផ្តល់ព័ត៌មានឲ្យយើង នៅលើវ៉ិបសៃរបស់យើង គឺជាការស្ម័គ្រចិត្តសុទ្ធសាធ ។ ព័ត៌មាននេះត្រូវបានប្រើ ដើម្បីបំរើអ្នកឲ្យបានល្អប្រសើរឡើង ។ ប្រសិនជាអ្នកជ្រើសរើសមិនផ្តល់ព័ត៌មានឲ្យខោនធី យីង សំរាប់ដាក់លើអ៊ិនទ័រណិតទេ អ្នកអាចផ្តល់ព័ត៌មាននេះឲ្យយើងតាមរបៀបផ្សេងទៀត ដូចជាការមកជួបការិយាល័យរបស់ខោនធីក្នុងពេលម៉ោងធ្វើការធម្មតា ឬសំរាប់សេវាខ្លះពីខោនធី ដោយបំពេញកិច្ចការរបស់អ្នកតាមទូរស័ព្ទ ឬតាមប្រៃសណីយ៍ ។
- នៅពេលខោនធី យីង ប្រមូលព័ត៌មានផ្ទាល់ខ្លួន ពីក្មេងៗដែលប្រើអ៊ិនទ័រណិត វាប្រតិបត្តិស្របតាមក្រឹត្យការពារភាពឯកជនរបស់ក្មេងៗនៃរដ្ឋបាលសហព័ន្ធ ដែលអាចរកឃើញនៅឯ http://www.ftc.gov/ogc/coppa1.html ។

វ៉ិបសៃរបស់ខោនធី យីង មានតភ្ជាប់ទៅនឹងវ៉ិបសៃដទៃទៀត រួមទាំងភ្នាក់ងាររដ្ឋាភិបាល អង្គការឥតយកកំរៃ និងក្រុមហ៊ុនឯកជន ។ នៅពេលអ្នកតភ្ជាប់ទៅវ៉ិបសៃខាងក្រៅណាមួយទាំងនេះ អ្នកមិននៅលើវ៉ិបសៃរបស់ខោនធី យីង ទៀតទេ ហើយប្រកាសន៍ភាពឯកជននេះ មិនពាក់ព័ន្ធទៀតឡើយ ។ ផ្ទុយទៅវិញ អ្នកត្រូវគោរពប្រកាសន៍ភាពឯកជននៃវ៉ិបសៃនោះ ។

## ពិនិត្យពិច័យ និងកែដំរូវ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក

នៅពេលមានសំបុត្រស្នើទៅភ្នាក់ងារណាមួយរបស់ខោនធី យីង អ្នកអាចនឹងពិនិត្យមើលព័ត៌មានផ្ទាល់ខ្លួនឡើងវិញ ដែលភ្នាក់ងាររក្សាទុកស្តីអំពីរូបអ្នក ហើយសូមភ្នាក់ងារនោះឲ្យកែអ្វីដែលខុស ។

នៅពេលមានសំបុត្រស្នើទៅភ្នាក់ងារណាមួយរបស់ខោនធី យីង អ្នកអាចនឹងទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលជាទូទៅសំគាល់កាលៈទេសៈដែលបានដឹង នូវព័ត៌មានផ្ទាល់ខ្លួនអ្វីមួយ ដែលមាននៅក្នុងបញ្ជីសាធារណៈរបស់ភ្នាក់ងារ អាចនឹងត្រូវបានបើកសំដែង ។

ដើម្បីឲ្យបានជ្រួតជ្រាបថែមទៀត សូមទាក់ទងទៅខោនធី យីង តាមរយៈអាស័យដ្ឋានអ៊ីមៀល ឬតាមលេខទូរស័ព្ទដែលមានកត់នៅខាងក្រោម ។

## ព័ត៌មានការទាក់ទង និង ភាសាផ្សេងទៀត

សំរាប់ការសាកសួរអំពីភាពឯកជន ឬជាភាសាផ្សេងទៀត សូមទាក់ទងទៅខោនធី ឃីង តាមរយៈអ៊ីមែល PrivacyContact@METROKC.gov ឬទុកសំឡេងនៅនឹងទូរស័ព្ទ តាមលេខ 206-205-6899 ។

(ភាសាបានផ្តល់ជូន ៖  ចិន, រុស្ស៊ី, វៀតណាម, ខ្មែរ, កូរ៉េ, លាវ និង អេស្ប៉ាញុល)

## ប្រកាសទ៍ភាពឯកជនផ្សេងទៀត របស់ខោនធី ឃីង

អង្គការខ្លះទៀតនៃខោនធី ឃីង អាចនឹងមានប្រកាសទ៍ភាពឯកជន ដែលតឹងរ៉ឹងខ្លាំងជាងព័ត៌មាននៃប្រកាសទ៍ភាពឯកជននេះ ។  នៅក្នុងករណីនោះ ប្រកាសទ៍ភាពឯកជនជាក់លាក់របស់អង្គការនោះ មានអំណាចលើព័ត៌មាននៃប្រកាសទ៍ភាពឯកជននេះ ។  សំរាប់ការសាកសួរអំពីប្រកាសទ៍ភាពឯកជននៃអង្គការណាមួយរបស់ខោនធី ឃីង សូមទាក់ទងទៅអង្គការនោះដោយផ្ទាល់តែម្តង ។

មានផ្តល់ជូនជាទំរង់ផ្សេងទៀត

206-205-6899     TTY បន្តសារ ៖ 711